

# ថ្ងៃព្រះពុទ្ធ

BUDDHA'S DAY

ប្រមូលរៀបរៀងដោយ

ភិក្ខុវិមលោ **សាន ថាវីន**

ធម្ម DHAMMA

បោះពុម្ពលើកទី ២

# ថ្ងៃព្រះពុទ្ធ

Buddha's day

ថ្ងៃសំខាន់នៃព្រះពុទ្ធសាសនា និងកំណាព្យធម៌ផ្សេងៗ
ចែកជាធម្មទានក្នុងឱកាសពិធីបុណ្យមាឃបូជា

ប្រមូលរៀបរៀងដោយ ភិក្ខុវិមលោ **សាន ថាវីន**

**ពុទ្ធសករាជ ២៥៦៥**

| | |
|---|---|
| សៀវភៅ | ថ្ងៃព្រះពុទ្ធ Buddha's day |
| ប្រមូលរៀបរៀងដោយ | ភិក្ខុវិមលោ **សាន ថាវីន** |
| ត្រួតពិនិត្យដោយ | ភិក្ខុចិត្តវុឌ្ឍោ **សុមេធ ឆព័ណ្ណ** |
| | សាមណេរគុណវឌ្ឍនោ **ម៉ាត ពិសិទ្ធិ** |
| វាយអត្ថបទ និងរចនាក្រប | ភិក្ខុវិមលោ **សាន ថាវីន** |
| ទីកន្លែងធ្វើ | វត្តភ្នំអណ្តើក ខេត្តបាត់ដំបង |
| កាលបរិច្ឆេទ | ពុទ្ធសករាជ ២៥៦៥ |
| បោះពុម្ពលើកទី ២ | ៥០០ ក្បាល |



# បោះពុម្ពជាធម្មទានដោយ

## ព្រះគ្រូសីលសំវរត្ថេរោ នៅ ច័ន្ទទាសនា

ព្រះធម្មធរអនុគណស្រុកបាណន់

និងជាព្រះចៅអធិការវត្តកច្ឆបបព៌ត “ភ្នំអណ្តើក”

# អារម្ភកថា

កូនសៀវភៅដ៏តូចប្រចឡឹង ដែលអ្នកកំពុងសំឡឹងមើលនេះ អាចមិនមានអត្ថសេចក្តីនៃព្រះធម៌ដ៏ជ្រាលជ្រៅទូលំទូលាយ តែក៏ជាកល្យាណមិត្តរបស់អ្នកទាំងអស់គ្នា ជាចំណែកមួយជួយដល់សតិបញ្ញា ក្នុងការបានដឹងនូវថ្ងៃសំខាន់របស់ព្រះពុទ្ធ ព្រមដោយប្រវត្តិនិងរឿងរ៉ាវខ្លះៗ ដែលអ្នកប្រាជ្ញបានចងក្រងទុកឲ្យយើងទាំងអស់គ្នាជាអ្នកគោរពព្រះពុទ្ធសាសនាបានយល់ដឹងនិងកំណត់ចំណាំទុកឲ្យសមជាបរិស័ទល្អ ។

ទីបញ្ចប់ សូមឲ្យអ្នកអានទាំងអស់គ្នា មានសេចក្តីសុខ សេចក្តីចម្រើនក្រោមម្លប់ព្រះពុទ្ធសាសនា និងសម្រេចតាមសេចក្តីប្រាថ្នាគ្រប់គ្នាចុះ ។

សូមអនុមោទនា!!!

# មាតិកានុក្រម

អាសាឡ្ហបូជា .......... ១
វិសាខបូជា .......... ២
មាឃបូជា .......... ៣
សាវ័កសន្និបាតប្រកបដោយអង្គ ៤ .......... ៤
អស្សុជបូជា .......... ៥
កត្តិកបូជា .......... ៦
នក្ខត្តបរិច្ឆេទ .......... ៧
បទសរភញ្ញ និងនមស្ការ .......... ៩
បទស្មូត្របង្ហូតទង់ព្រះពុទ្ធសាសនា .......... ១១

បទសូត្រដាក់ទង់ព្រះពុទ្ធសាសនា ........ ១៣
កំណើតរស្មីទាំង ៦ ពណ៌ ........ ១៦
ព្រះអង្គដាក់អាយុសង្ខារ ........ ១៩
គោតមប្រវត្តិ ........ ២៤
ពុទ្ធកិច្ច ៥ យ៉ាង ........ ៣០
វិសាខបុណ្ណមី ........ ៣៤
ឋានត្រៃរតនៈ ........ ៣៧
ស្រឡាញ់តាមធម៌ ទើបល្អជីវិត ........ ៣៩
បុណ្យជាអ្វី ........ ៤២
សមរភូមិក្លាខ្លាំងដេញខ្ទាំងក្នុងខ្លួន ........ ៤៣

ដងទង់ខ្ពស់ល្អ ........ ៤៤
គុណរបស់ទាន ........ ៤៦
សេចក្ដីត្រិះរិះរបស់នាងវិសាខា ........ ៤៧
អធិដ្ឋានការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ ........ ៤៩
សម្រស់វេឡុវ័នមហាវិហារ ........ ៥១
ធម៌នមស្ការព្រះពោធិសត្វទាំង ១១ ព្រះអង្គ ........ ៥៣
គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ ៤ គាថា ........ ៦២
គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ ........ ៦៥
បទដ៏ប្រសើរ ........ ៧៨
រលឹកដល់ព្រះរតនត្រៃរឿយៗ ឈ្មោះថាជាសាវ័កល្អ ........ ៨៤

ពាក្យឧទ្ទិសបុណ្យ........................................................................................ ៨៩
ពាក្យផ្សាយមេត្តាចិត្ត................................................................................... ៨៩
របៀបសំពះតាមប្រពៃណីខ្មែរ........................................................................ ៩០
អានិសង្សការសំពះ....................................................................................... ៩៥
របៀបថ្វាយបង្គំ........................................................................................... ៩៦

**អប្បកា វាលុកា គង្គា**
**អនន្តា និព្វុតា ជិនា**
**តេ តេសំ ធម្មសង្ឃញ្ច**
**អាទរេន នមាមិហំ ។**

ព្រះជិនស្រីទាំងឡាយ បរិនិព្វានទៅហើយ ច្រើនជាអនន្ត ប្រៀបបាននឹងគ្រាប់ខ្សាច់ដែលមិនមែនតិចនៅនឹងទន្លេគង្គា ខ្ញុំសូមនមស្ការនូវព្រះជិនស្រីទាំងឡាយនោះផង នូវព្រះធម៌ និងព្រះសង្ឃរបស់ព្រះជិនស្រីទាំងឡាយនោះផង ដោយគោរព ។ (ឆន្ទោសារត្ថមេទិនី)

# អាសាឡ្ហបូជា

## (ថ្ងៃ១៥ កើត ខែអាសាឍ)[១]

១-ព្រះអង្គទ្រង់ចុះកាន់គភ៌ព្រះមាតា (ចាប់បដិសន្ធិ)
២-ព្រះអង្គទ្រង់ចេញបួស
៣-ព្រះអង្គទ្រង់សម្ដែងធម្មចក្ក (បឋមទេសនា)
៤-ព្រះអង្គទ្រង់សម្ដែងយមកប្បាដិហារ្យ (ផ្ចាញ់ពួកនិគ្រន្ថ) ។

[១] ឆ្នាំដែលមានអធិកមាសអាសាឡ្ហបូជានៅក្នុងថ្ងៃ ១៥ កើត ខែទុតិយាសាឍ ។

# វិសាខបូជា

(ថ្ងៃ១៥ កើត ខែ វិសាខ)

១-ព្រះអង្គទ្រង់ប្រសូតិ

២-ព្រះអង្គទ្រង់ត្រាស់ដឹងជាព្រះពុទ្ធក្នុងលោក

៣-ព្រះអង្គទ្រង់បរិនិព្វាន ។

# មាឃបូជា

(ថ្ងៃ១៥ កើត ខែ មាឃ)

១-ប្រជុំសាវ័កសន្និបាត

២-ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ។

# សាវ័កសន្និបាតប្រកបដោយអង្គ ៤

១-ថ្ងៃនោះជាថ្ងៃ ១៥ កើត ប្រកបដោយមាឃនក្ខត្តឫក្ស

២-ភិក្ខុ ១,២៥០ រូប ប្រជុំគ្នាតាមធម្មតារបស់ខ្លួន មិនមានអ្នកណានិមន្ត

៣-ភិក្ខុទាំងនោះ មិនមានសូម្បីត្រឹមតែ ១ រូប ដែលជាបុថុជ្ជន ឬព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី និងព្រះអរហន្តសុក្ខវិបស្សកទេ ភិក្ខុទាំងអស់ជាអ្នកបាន អភិញ្ញា ៦ ទាំងអស់ ។

៤-ភិក្ខុទាំងនោះមិនបានកោរសក់ដោយកាំបិតកោរបួសសូម្បីត្រឹមតែ ១ រូប ភិក្ខុទាំងអស់ជាឯហិភិក្ខុ ។ (ចាកអដ្ឋកថាទីឃនខសូត្រ)

# អស្សុជបូជា

## (ថ្ងៃ ១៥ កើត ខែ អស្សុជ)

១-ព្រះអង្គទ្រង់ចុះចាកឋានតាវត្តិង្ស (បន្ទាប់ពីបានប្រោសពុទ្ធមាតារួច)

# កត្តិកបុណ្យ

- <u>ថ្ងៃ ១៥ កើត ខែកត្តិក</u> ជាថ្ងៃដែលទន្សាយព្រះពោធិសត្វឈ្មោះ សសបណ្ឌិត បំពេញទានបរមត្ថបារមី (ឱ្យជីវិតជាទាន)។
- <u>ថ្ងៃ ១៥ កើត ខែកត្តិក</u> ជាថ្ងៃព្រះធម្មសេនាបតីសារីបុត្រជាអគ្គសាវ័កស្តាំ និង ជាឯតទគ្គៈផ្នែកខាងជាអ្នកមានបញ្ញាច្រើន ចូលបរិនិព្វាន ។
- <u>ថ្ងៃ ១៥ រោច ខែកត្តិក</u> ជាថ្ងៃព្រះមហាមោគ្គល្លានជាអគ្គសាវ័កឆ្វេង និងជា ឯតទគ្គៈផ្នែកខាងជាអ្នកមានឫទ្ធិច្រើន ចូលបរិនិព្វាន ។

# នក្ខត្តបរិច្ឆេទ[១]

**មហាបុរិសោ បន ឧត្តរាសាឡ្ហនក្ខត្តេនេវ មាតុកុច្ឆឹ ឱក្កមិ, មហាភិនិក្ខមនំ និក្ខមិ, ធម្មចក្កំ បវត្តេសិ, យមកបាដិហារិយំ អកាសិ។** ដោយនក្ខត្តឫក្ស គឺផ្កាយនក្ខត្តឫក្សក្នុងខែឧត្តរាសាឡ្ហ (ខែអាសាឍ) ព្រះមហាបុរស យាងចុះកាន់ព្រះគភ៌ព្រះជននី, ទ្រង់ចេញមហាអភិនេស្រ្កមណ៏,

ទ្រង់ប្រកាសព្រះធម្មចក្ក ទ្រង់សម្ដែងយមកប្បាដិហារ្យ ។

**វិសាខនក្ខត្តេន ជាតោ ច អភិសម្ពុទ្ធោ ច បរិនិព្វុតោ ច ។** ដោយនក្ខត្តឫក្ស គឺផ្កាយនក្ខត្តឫក្ស ក្នុងខែវិសាខ ទ្រង់ប្រសូត្រ ១ ត្រាស់ដឹង ១ បរិនិព្វាន ១ ។

---

[១] ពុទ្ធវំសអដ្ឋកថា ពុទ្ធបកិណ្ណកកថា

**មាឃនក្ខត្តេន តស្ស សាវកសន្និបាតោ ច អាយុសង្ខារវោសជ្ជនញ្ច អហោសិ ។** ដោយនក្ខត្តឫក្ស គឺផ្កាយនក្ខត្តឫក្សខែមាឃ ព្រះអង្គទ្រង់ប្រជុំព្រះសាវ័ក (សាវ័កសន្និបាត) ១ ទ្រង់ដាក់អាយុសង្ខារ ១ ។

**អស្សយុជនក្ខត្តេន ទេវោរោហណំ ។** ដោយនក្ខត្តឫក្ស គឺផ្កាយនក្ខត្តឫក្សខែអស្សុជ ទ្រង់ចុះចាកទេវលោក (ជាន់តាវត្តិង្ស) ។

**អយំ នក្ខត្តបរិច្ឆេទោតិ** នេះឈ្មោះថា កំណត់នក្ខត្តឫក្ស ។

# បទសរភញ្ញ និងនមស្ការ

សូមថ្វាយបង្គំព្រះសម្មុទ្ធ ប្រសើរបំផុតក្នុង លោកា
ជាគ្រូនៃមនុស្សនិងទេវតា ទ្រង់ត្រាស់ទេសនាប្រដៅសត្វ។
ចង្អុលឱ្យដើរផ្លូវកណ្ដាល មាគ៌ាត្រកាល អាចកម្ចាត់
ទុក្ខភ័យចង្រៃ ឱ្យខ្លាយបាត់ អាចកាត់សង្សារទុក្ខបាន។
សាសនាព្រះអង្គ នៅសព្វថ្ងៃ សត្វមាននិស្ស័យ ពីបូរាណ
ប្រឹងរៀនប្រឹងស្ដាប់ ចេះចាំបាន កាន់តាមលំអាន បានក្ដីសុខ។
ឥតមានសុខណាស្មើក្ដីស្ងប់ បញ្ចប់ត្រឹមសុខ ឃ្លាតចាកទុក្ខ

តាំងពីលោកនេះ តទៅមុខ ក្ដីសុខនឹងមាន ព្រោះធម៌ស្ងប់។
ខ្ញុំសូមបង្គំ ឆ្ពោះព្រះធម៌ ព្រះសង្ឃបវរ ទាំងគ្រប់សព្វ
រួមជាត្រៃរ័ត្ន គួរគោរព ជាម្លប់ត្រជាក់ នៃលោកា។
ព្រះរូបព្រះធាតុ នៃព្រះពុទ្ធ វិសុទ្ធតាំងអង្គ ព្រះសាស្ដា
សូមគុណត្រៃរ័ត្ន ជួយខេមរា ឱ្យបានសុខា តរៀងទៅ! ។

# បទសូត្របង្ហូតទង់ព្រះពុទ្ធសាសនា

( បទបឋ្យាវត្ត )

សូមមើលទង់ជ័យឆព្វណ្ណរង្សី ដែលមានរស្មី ភ្លឺស្រស់ល្អ
ខៀវលឿងក្រហមព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ ដ៏ភ្លឺផ្លេក ។
ប្រទេសតូចធំបានស្ម័គ្រស្មាគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មីព្រះពុទ្ធគួរត្រេក ប្រសើរពន់ពេកក្រៃកន្លង។
ធ្វើជាសញ្ញាទង់ជ័យសាសនា នៃព្រះសម្ពុទ្ធធំចម្បង
ចូរយើងរាល់គ្នាយកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់។
ទោះជាតិផ្សេងគ្នាក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍

ត្រូវមានសាមគ្គីទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗ គ្នា។
សូមសាសនាពុទ្ធថ្កុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគផ្សាយពេញលោកា ដោយជនជ្រះថ្លារាប់ច្រើនលាន។
មានចិត្តស្នេហាគោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតាស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ។
យើងខេមរជាតិនាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គីពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។
ព្រមព្រៀងប្រព្រឹត្តកាន់ធម៌សុចរិត ឆ្ពោះទៅកាន់ឋាននិព្វាន
ជាទីផុតទុក្ខបានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

# បទសូត្រជាក់នង់ព្រះពុទ្ធសាសនា

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរង្គប្រសើរបវរ
ផ្សៀលឆ្វាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ។
រស្មីពណ៌ខៀវនោះណា កាលផ្តៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីភិរាស្ត្រ។

រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អាសាច់ផែផ្ញើមាស
បិតពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទ្រជាងមាសទ្រង់វៃបណ្ឌិត។
រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស្ទូបប្តូរជីវិត កាត់បេះដូងបិទផ្ញើថ្នាំមាតា។
រស្មីពណ៌សសុទ្ធសាធ កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញាណ។
រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់យក្ខចាប់យកបាន
វិជ្ជាធរអាសាច់ខ្លួនប្រាណ ឱ្យយក្ខសាមាន្យស៊ីប្តូរជីវិត។
រស្មីពណ៌ផ្លែកពណ្ណរាយ កាលជាទន្សាយឈ្មោះសោមបណ្ឌិត

ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍ពិតថាអត់អាហារ។
រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ក្មេងចាស់កុមារចូរចាំទុកអើយ៕

# កំណើតទង់ជ័យទាំង ៦ ពណ៌

ពណ៌ខៀវកាលផ្ទៀលព្រះនេត្រា ឱ្យឥន្ទព្រាហ្មណ៍ណាកាលជាស្តេច
នាមស្រីភិរាស្រួចចង់សម្រេច ឱ្យបានសារពេជ្ជសាស្តាចារ្យ ។
ពណ៌លឿងកាលអារសាច់ធ្វើមាស បិទលនអង្គព្រះពុទ្ធបដិមា
ព្រះឥន្ទជាជាងច្នៃរចនា ថ្វាយពរសាធុការពេញផែនដី ។
ក្រហមជាពណ៌ឈាមបេះដូង ផ្ទៀលពីដើមទ្រូង ដោយឃ្នាតខ្វី
បិទពិសពស់ខាំ ព្រះជនី គង់រស់ជីវី ជាស្បើយទៅ ។
ពណ៌សឱ្យទានដំរីស មង្គលបវរ មាសឆ្អិនឆ្អៅ

ត្រូវវាស្រួលបណ្ដេញមិនឱ្យនៅ ព្រមទាំងកូនចៅភរិយាណា ។
ហង្សបានលោហិតសាច់មំសំ អារសាច់ខ្លួនតាំង ជូនមាតា
កាលយក្ខវាចាប់បរិភោគ្គា ជីវិតមាតា រស់រឹងខ្ជី ។
ផ្ទេកពណ្ណរាយ កាលជាទន្សាយ ឱ្យទានពុំស្ដាយ ជីវិតអី
លោតចូលភ្នក់ភ្លើង ពុំថាអ្វី ឱ្យជាចំណី ឥន្ទព្រាហ្មណ៍ណា ។
កាលដែលបានត្រាស់ ជាព្រះពុទ្ធ ជាមកុដត្រៃភព ក្នុងលោកា
ពណ៌ទាំងប្រាំមួយ នេះសោតណា ក្លាយមកកើតជា ឆព្វណ្ណរង្សី ។
ពេលនេះក្នុងលោក គេសន្មត យកពណ៌នេះកត់ ជាសេចក្ដី
ហៅទង់សាសនា ព្រះជិនស្រី ពាសពេញផែនដី ផ្ទៃពសុធា ។

យើងខ្ញុំរាល់គ្នា សូមគោរព វន្ទាចមភព ទង់សាសនា
សូមមានមង្គលឈ្នះមារា សត្រូវនានា ក្នុងភពបី ។
សូមឱ្យយើងខ្ញុំ ប្រញាប់ដល់ ដើរកាត់តាមផ្លូវ ទៅបុរី
ជាស្ថានបរមសុខសួស្តី ដោយព្រះបារមី និព្វានហោង ។

# ព្រះអង្គដាក់អាយុសង្ខារ

អង្គព្រះទ្រង់ញាណមានតេជះ សម្តែងប្រាប់ព្រះអានន្ទថា
រទេះដែលចាស់បរទៅណា ទៅបានដោយសារអបឫស្សី ។
តថាគតចាស់គ្រាំគ្រាហើយ ម្នាលអានន្ទអើយមានមាំអី
ដូចរទេះចាស់អបឫស្សី វស្សាឆ្នាំថ្មីប៉ែតសិបហើយ ។
ក្រោយព្រះអានន្ទទ្រង់ចេញផុត ពីព្រះសម្ពុទ្ធមិនយូរឡើយ
ក្រោយភត្តាហារថ្ងៃត្រង់ហើយ មារមិនកន្តើយគាល់សាស្តា ។
ឆ្នាំម្សាញ់ខែមាឃថ្ងៃអាទិត្យ ពេញបូណ៌មីពិតថ្ងៃនោះណា

ព្រះអង្គទ្រង់ដាក់អាយុសង្ខារ ចំពោះមុខមារគ្រានោះឯង ។
នៅនាបាវាលចេតិយ ក្បែរវេសាលីក្រៅកំផែង
កក្រើកធរណីគ្រប់កន្លែង ផ្គរលាន់ខ្ទាត់ខ្ទែងខ្ទរអាកាស ។
ក្រោយមកភិក្ខុជួបជុំគ្នា អង្គព្រះភគវាទ្រង់បានត្រាស់
សម្ដែងគាថាអស្ចារ្យណាស់ រំលឹកយ៉ាងច្បាស់ត្រាស់ឱវាទ ។
ទ្រង់បានត្រាស់ថាសង្ខារទាំងឡាយ តែងតែអន្តរាយវិនាសខូចខាត
ចូរអ្នកទាំងឡាយកុំបីប្រមាទ ប្រឹងប្រែងសង្វាតឱ្យសម្រេចការ ។
ភាជន៍ដែលស្មូនឆ្នាំងដំដុតដោយដី តូចក្ដីធំក្ដីឆៅឆ្អិនយ៉ាងណា
ចុងក្រោយរមែងតែងមានកិរិយា បែកធ្លាយធម្មតានេះជាការពិត ។

យ៉ាងណាជីវិតសព្វសត្វនិករ ក្មេងចាស់មានក្រពាលឬបណ្ឌិត
ចុងក្រោយរមែងតែងតែស្លាប់ពិត បាត់បង់ជីវិតក៏យ៉ាងនោះដែរ ។
ជីវិតតថាគតមានប្រមាណតិច គោរពពាក្យពេចន៍ឥតគេចកែប្រែ
ពីថ្ងៃនេះទៅនៅត្រឹមបីខែ តថាគតត្រូវតែបរិនិព្វាន ។
បីខែកន្លងយ៉ាងរហ័ស សែនសោកស្តាយណាស់ព្រះទ្រង់ញាណ
វេលាជិតភ្លឺទ្រង់ចូលឈាន ហើយចូលនិព្វានកណ្តាលព្រៃ ។
ក្នុងខែពិសាខថ្ងៃអង្គារ ឆ្នាំម្សាញ់វេលាចុងរាត្រី
ថ្ងៃដប់ប្រាំកើតពេញបូណ៌មី បរិស័ទប្រុសស្រីជុំត្រៀបត្រា ។
ទីទ្រង់និព្វាននោះតាំងនៅ ក្បែរផ្លូវទៅក្រុងកុសិនារា

រាំងភ្នំមួយគួសាលព្រឹក្សា មានផ្ទាំងសិលានៅចន្លោះ ។
កុំថាឡើយមនុស្សសោយសោកា សូម្បីទេវតាស្ថានទាំងអស់
យំសោកបោកប្រាណស្តាយស្រណោះ លាន់កក្រើកអស់ភពផែនដី ។
ទីទ្រង់និព្វាននោះឥឡូវ មានស្តូបតាំងនៅល្អប្រិមប្រិយ
សម្គាល់ទីដែលព្រះជិនស្រី និព្វានលើដីកុសិនារា ។
ក្នុងស្តូបមានព្រះបដិមាថ្ម កសាងយ៉ាងល្អគួរជ្រះថ្លា
តំណាងព្រះសពព្រះសាស្តា ស្តូកស្តឹងកាយាសែនអាសូរ ។
អ្នកទៅដល់ពិតចិត្តជិតជាប់ ឃើញដូចព្រះសពនៅជ្រងោ
មានស្បង់ចីវរថ្វាយផ្លាស់ប្តូរ ទឹកនេត្រាហូរនឹកព្រះអង្គ ។

នឹកហាក់ដូចជានៅថ្មី ៗ
នឹកដល់ព្រះធម៌ល្អផូរផង់
ចាប់តាំងអំពីថ្ងៃនេះទៅ
ក្រោមម្លប់ព្រះធម៌ដ៏ត្រជាក់
សូមឱ្យលោកអ្នកបានសូធ្យស្ដាប់
បានសុខចម្រើនគ្រប់ៗគ្នា

នឹកព្រះជិនស្រីប្រោសស្រោចស្រង់
នឹកទាំងព្រះសង្ឃអង្គសាវ័ក ។
សូមដើរតាមផ្លូវព្រះអរិយៈ
ផុតពីអន្ទាក់នៃពួកមារ ។
ប្រវត្តិសាសព្ទព្រះភគវា
កុំបីឃ្លាតឃ្លាគ្រាណាឡើយ ។

# គោតមប្រវត្តិ

ខ្ញុំសូមថ្វាយវន្ទា ព្រះសាស្ដាដ៏មានបុណ្យ
និងសូមគោរពគុណ គ្រាព្រះអង្គចុះចាកឋាន។
មកចាប់ផ្ទៃមាតា ស្រីស្រីង្គាររស្រស់កល្យាណ
កាលនោះមហាជនបាន សុខក្សេមក្សាន្តព្រោះបារមី ។
ក្នុងថ្ងៃព្រហស្បតិ៍អា- សាធមាសាពេញបូណ៌មី
រកាជាឆ្នាំថ្មី សុខសិរីដល់ជនា ។
កាលបាន១០ខែហើយ ព្រះគុណអើយកើតអស្ចារ្យ

នៅនាដងព្រឹក្សា ឈ្មោះហៅថាព្រៃសាលវ័ន ។
កក្រើកផែនពសុធា មានទេវតារាប់រយពាន់
ស្ថិតនៅក្នុងតំបន់ នៃឧទ្យានលុម្ពិនី ។
ឆ្នាំចពិសាខនា ថ្ងៃសុក្រជាពេញបូណ៌មី
ថ្ងៃនោះព្រះជិនស្រី ទ្រង់ប្រសូតឥតមានព្រួយ ។
កាលសិទ្ធត្ថក្សត្រា មានវស្សាដប់ប្រាំមួយ
បិតាបានលើកស្នួយ អភិសេកនឹងស្រីង្គារ ។
នារីស្រស់កល្យាណ អ្នកផងបានស្គាល់គ្រប់គ្នា
ថាឈ្មោះនាងពិម្ពា ស្រស់សោភាលើសលែងក្រៃ ។

កាលនោះក្នុងឆ្នាំឆ្លូវ ត្រូវថ្ងៃសៅរ៍មានសិរី
អាសាឍពេញបូណ៌មី ក្សត្រាថ្ងៃបានសុខា ។
ស្តេចមានព្រះរាជបុត្រ បរិសុទ្ធភ័ក្ត្រស្រស់ថ្លា
គួរឱ្យព្រះរាជា ស្តេចជំពាក់ចិត្តពេកក្រៃ ។
តែទ្រង់បានកាត់ផ្តាច់ ទ្រង់សម្រេចព្រះហឫទ័យ
ថាត្រូវកាត់អាល័យ ពីបុត្រថ្លៃមួយគ្រាណា ។
បើបិតាបានត្រាស់ វិលរហ័សរកបុត្រា
មកប្រោសស្ងួនពុំងា ចាកសង្សារណាបុត្រថ្លៃ ។
កាលនោះថ្ងៃព្រហស្បតិ៍ ក្នុងឆ្នាំថោះមានសិរី

អាសាឍពេញបូណ៌មី ក្សត្រាថ្ងៃចេញបព្វជ្ជា ។
កាលបានបព្វជ្ជាហើយ មិនព្រងើយខំឧស្សាហ៍
ធ្វើទុក្ករកិរិយា គ្មាននរណាធ្វើដូចអី ។
បានត្រាស់ឆ្នាំរកា ពិសាខាពុធបុណ្ណមី
ជាថ្ងៃព្រះជិនស្រី មានសិរីឈ្នះក្រុងមារ ។
ត្រាស់ដឹងបានពីរខែ ទ្រង់គ្មាន់គ្នេរប្រោសទេសនា
ប្រោសបញ្ចវគ្គិយា នាកណ្តាលដងព្រឹក្សព្រៃ ។
គឺក្នុងឆ្នាំរកា អាសាឍមាសាបុណ្ណមី
ថ្ងៃសៅរ៍ព្រះជិនស្រី ផ្តើមពោលស្តីធម៌ទេសនា ។

ក៏ជាថ្ងៃកំណើត សង្ឃបានកើតក្នុងលោកា
សាវ័កព្រះសាស្តា មានរហូតដល់សព្វថ្ងៃ ។
នាថ្ងៃមួយនោះណា គួរសោកាណាស់ម្ចាស់ថ្លៃ
គឺថ្ងៃព្រះជិនស្រី កាត់ព្រះទ័យដាក់សង្ខារ ។
គឺក្នុងថ្ងៃអាទិត្យ ឆ្នាំម្សាញ់ពិតមាឃមាសា
នៅចំពោះមុខមារ នាបាវាលចេតិយ ។
បីខែកន្លងទៅ មិនឈប់នៅឃើនយូរអី
ដល់ថ្ងៃព្រះជិនស្រី ទ្រង់និព្វានចាកលោកា ។
គឺក្នុងឆ្នាំនោះឯង មានការផ្សេងតែមាសា

គឺខែពិសាខនា ថ្ងៃអង្គារពេញបូណ៌មី ។
ដោយអំណាចអានុភាព ដែលខ្ញុំក្រាបថ្វាយវន្ទីយ៍
នឹកគុណព្រះមុនី សូត្រប្រវត្តិព្រះសាស្តា ។
សូមឱ្យសម្រេចបុណ្យ ដែលជាគុណល្អថ្លៃថ្លា
អន្ទោលក្នុងសង្សារ សូមប្រាថ្នាជួបបណ្ឌិត ។
សូមជួបព្រះសិអារ្យ ជាសាស្តាដ៏ពិសិដ្ឋ
សូមចាក់ធ្លុះធម៌ពិត សមដូចចិត្តប្រាថ្នាហោង៕

# ពុទ្ធកិច្ច ៥ យ៉ាង

យើងខ្ញុំបរិស័ទពុទ្ធសាសនា ឱនកាយវាចាចិត្តគោរព
ចំពោះព្រះពុទ្ធដែលជាម្លប់ គ្រប់គ្នាត្រូវចាំឱ្យទៀងទាត់ ។
ចងចាំថ្ងៃខែឱ្យបានច្បាស់ នៃព្រះពុទ្ធម្ចាស់គឺប្រវត្តិ
សង្ខេបខ្លីៗ ឱ្យរត់មាត់ កំណត់ចាំបានពេលទាំងអស់ ។
យាងចុះកាន់គភ៌ឆ្នាំរកា អាសាឍមាសាថ្ងៃព្រហស្បតិ៍
ប្រសូតឆ្នាំច ថ្ងៃសុក្រស្មោះ ពិសាខឈើលាស់ដើមរដូវ ។
សោយរាជ្យកត្តិកថ្ងៃអាទិត្យ ប្រជុំព្រាហ្មណ៍ព្រឹទ្ធនាឆ្នាំឆ្លូវ

បួសថោះអាសាឍព្រហស្បតិ៍ត្រូវ    ត្រាស់នៅរកាពិសាខពុធ ។
បរិនិព្វានថ្ងៃអង្គារ    បរិស័ទគ្រប់គ្នាកើតតក់ស្លុត
នៅខែពិសាខព្រះសម្ពុទ្ធ    រលត់បញ្ចក្ខន្ធនាឆ្នាំម្សាញ់។
យើងបាត់ព្រះពុទ្ធទាន់សាសនា    ធម៌ជាអាចារ្យកុំគ្នាន់ក្នាញ់
អ្នកប្រព្រឹត្តធម៌ឈ្មោះស្រឡាញ់    ចំពោះអង្គអញតថាគត ។
បំណាច់អ្នកកាន់ពុទ្ធសាសនា    ត្រូវចាំសារតារនៃព្រះពុទ្ធ
គឺថ្ងៃខែឆ្នាំឱ្យហ្មត់ចត់    ទើបបានកំណត់ជាពុទ្ធជន ។
ពុទ្ធកិច្ចប្រាំយ៉ាងគឺអ្វីខ្លះ    ចូរចាំឱ្យច្បាស់គ្រប់រូបា
បំណាច់អ្នកកាន់ពុទ្ធសាសនា    ត្រូវចាំកិច្ចការនៃព្រះអង្គ ។

ពេលព្រឹកទ្រង់យាងបិណ្ឌបាត តាមផ្ទះមានញាតិចាំរហង់
ជូនមួយអង្គឯងជូនមានសង្ឃ តម្រង់តាមសត្វមាននិស្ស័យ ។
រសៀលទ្រង់ត្រាស់សម្តែងធម៌ ដល់សត្វនិករដោយអាល័យ
បើសត្វមិនយល់ទ្រង់ឧបមេយ្យ បកស្រាយសេចក្តីឱ្យយល់បាន។
ព្រលប់ប្រទានព្រះឱវាទ ដល់សង្ឃឱ្យស្អាតល្អកល្យាណ
កុំឱ្យប្រព្រឹត្តខុសលំអាន តាមផ្លូវដែលបានទ្រង់បញ្ញត្តិ ។
អធ្រាត្រទ្រង់ដោះស្រាយបញ្ហា ដែលពួកទេវតាមកច្រើនក្តាត់
សម្តែងព្រះសូត្រឬបរមត្ថ តាមពួកសត្វដែលសង្ស័យ ។
ជិតភ្លឺប្រមើលនិស្ស័យសត្វ តើអាចប្រតិបត្តិមានកម្រៃ

ដែលគួរត្រាស់ដឹងព្រះធម៌ថ្លៃ    តាមឧបនិស្ស័យសត្វលោកា ។
៤៥ ឆ្នាំឥតមានខ្វះ    ព្រះអង្គនឿយណាស់លើសមនុស្សា
ឥតមានសម្រាកព្រះកាយា    ឥតមាននរណាប្រដូចបាន ។
យើងបាត់ព្រះពុទ្ធទាន់សាសនា    ធម៌ជាអាចារ្យទូន្មានប្រាណ
ប្រព្រឹត្តត្រង់ផ្លូវត្រូវលំអាន    ដរាបដល់បាននិព្វានហោង ។

# វិសាខបុណ្ណមី

វិសាខបុណ្ណមីគឺថ្ងៃវិសេស យើងបានចាំចេះថ្ងៃព្រះភគវា
ប្រាំពីរប្រការជ្រះថ្លាវន្ទា វិសាខបូជាបូក្សពារសែនល្អ។
ទីមួយគឺថ្ងៃសុមេធបណ្ឌិត ពោធិសត្វពិតមានឫទ្ធិបវរ
ចាប់ផ្ដើមទទួលព្រះពុទ្ធព្យាករណ៍ លោកធាតុញាប់ញ័រសាទរពេកក្រៃ។
ទីពីរគឺថ្ងៃក្សត្រថ្ងៃប្រសូត អស្ចារ្យរហូតសម្ដោធព្រឹក្សព្រៃ
កំណើតចុងក្រោយជាប់ដោយអត្ថន័យ ផុតចាកភពត្រៃលែងភ័យលែងព្រួយ។

ទីបីគឺថ្ងៃព្រះស្រីមហាពោធិ៍
ផុះចេញលេចធ្លោពោធិ៍ពិតមានត្រួយ
ថ្ងៃព្រះប្រសូតស្រូតផុះជាមួយ
ជំនួយឱ្យចិត្តបរិស័ទជ្រះថ្លា។
ទីបួនគឺថ្ងៃចម់ត្រែត្រាស់ដឹង
ថ្ងៃមានទីពឹងពំនឹងលោកា
ជាថ្ងៃព្រះពុទ្ធបរិសុទ្ធអស្ចារ្យ
ពួកជនជ្រះថ្លាចិន្តាល្អស្អាត។
ទីប្រាំគឺថ្ងៃអង្គថ្លៃនិព្វាន
ថ្ងៃព្រះទ្រង់ញាណមានពុទ្ធោវាទ
បច្ឆិមវាចាថាកុំប្រមាទ
ឱវាទពិសិដ្ឋឋិតនៅជាគ្រូ។
ប្រាំមួយគឺថ្ងៃប្រល័យព្រះធាតុ
ចេតិយលោកនាថនៅទៀតមិនយូរ
ព្រះធាតុទាំងអស់ហោះមកគល់ពោធិ៍
តេជោរំលាយរលត់ពុទ្ធសាសន៍។
ប្រាំពីរគឺថ្ងៃជោគជ័យពុទ្ធា
គ្រប់ព្រះភគវាឈ្នះមារបានត្រាស់

នាំមកនូវសុខវិសេសខ្លាំងណាស់ គ្រប់អង្គទ្រង់ត្រាស់ព្រះធម៌ទេសនា។
វិសាខបុណ្ណមីថ្ងៃប្រពៃពិត យើងខ្ញុំមានចិត្តនឹងធឹងជ្រះថ្លា
វន្ទាសំពះអង្គព្រះសាស្តា សូត្រធម៌ថ្វាយផ្កាបូជាប្រទីប។

# បាណត្រៃរតនៈ

ក្រុងពារាណសីទឹកដីពោធិសត្វ ក្នុងសង្សារវដ្តបំពេញបារមី
ព្រះបាទព្រហ្មទត្តគ្រងដែនកាសី ព្រះពោធិសត្វថ្ងៃបួសជាតាបស ។
ឥសិបតនៈព្រៃមិគទាយា ឋានព្រះភគវាគ្រប់អង្គទាំងអស់
សម្តែងធម្មចក្កប្រោសពួកតាបស អរិយមគ្គខ្ពង់ខ្ពស់បឋមទេសនា។
អាសាឍបុណ្ណមីថ្ងៃកំណើតធម៌ ទេសនាបវរមជ្ឈិមាយាត្រា
ជាថ្ងៃកំណើតព្រះធម៌ទេសនា បរិស័ទជ្រះថ្លាថ្វាយផ្កាចេតិយ ។
អាសាឍបុណ្ណមីថ្ងៃកំណើតសង្ឃ សរណៈពេញអង្គសង្ឃគម្រប់បី

ឋានត្រៃរតនៈក្នុងដែនកាសី អាសាឍបុណ្ណមីអាសាឡ្ហបូជា ។
ចេតិយព្រះយសខ្ពស់ព្រោះសសរ យសបានស្តាប់ធម៌តលំដាប់គ្នា
ឯហិភិក្ខុដោយព្រះភគវា ព្រះយសបានជាសង្ឃព្រះអរហន្ត ។
ហាសិបបួនអង្គសម្លាញ់ព្រះយស មកបួសទាំងអស់ព្រៃមិគទាយវ័ន
ឋានត្រៃរតនៈឋានព្រះភគវ័ន្ត ត្រាស់ប្រាប់អរហន្តចេញផ្សាយសាសនា។
ខ្ញុំសូមបង្គំឋានត្រៃរតនៈ ដោយចិត្តស្មោះស្ម័គ្រនឹកព្រះសាស្តា
នឹកព្រះអរហន្តនឹកធម៌ទេសនា ខ្ញុំសូមប្រាថ្នាផុតកាមលោកិយ ។

# ស្រឡាញ់តាមធម៌ ដើបល្អជីវិត

ស្រឡាញ់ក៏ស្រឡាញ់ទៅចុះ
ប្រុសស្រីស្រួលស្រុះលុះសីលធម៌
កុំតែស្រឡាញ់ឱ្យវឹកវរ
បង្កអាស្រូវនៅក្នុងស្រុក ។
សីលធម៌សង្គមប្រពៃណី
យើងរួមសាមគ្គីរក្សាទុក
ខ្មែរស្រឡាញ់ខ្មែរខ្មែរមានមុខ
ខ្មែរយើងមានស្រុកមានវប្បធម៌ ។
ខ្មែរស្លៀកពាក់ខ្មែរនិយាយខ្មែរ
ខ្មែរមានឪម៉ែអ្នកអង្គរ
ខ្មែរមានអរិយធម៌ខ្ពស់បវរ
ខ្មែរមានអក្សររបស់ខ្លួន ។
ខ្មែរនាំគ្នាកាន់សាសនាពុទ្ធ
ខ្មែរចិត្តមោះមុតជាតិមាំមួន
ខ្មែរមានបិដកភាសាខ្លួន
ខ្មែរមានច្បាប់ក្បួនខ្មែរមានធម៌។

ខ្មែរយើងជាពូជអ្នកល្បាញល្បី ខ្មែរមានទឹកដីព្រៃអង្គរ
ខ្មែរមានប្រាសាទល្បីខ្ទារខ្ទរ ខ្មែរម្ចាស់អង្គរបន្តថៃ។
ខ្មែរមានព្រះសង្ឃខ្មែរមានវត្ត ខ្មែរមានបែបបទរបស់ខ្មែរ
ខ្មែរទទួលស្គាល់គុណឪម៉ែ ខ្មែរចេះធ្វើស្រែខ្មែរមានបាយ។
ខ្មែរស្រឡាញ់ខ្មែរខ្មែរថែខ្លួន ខ្មែរជាតិមាំមួនខ្មែរសប្បាយ
ខ្មែររួមប្រជុំជាតិទាំងឡាយ ខ្មែរមានឧបាយកសាងជាតិ។
ខ្មែរធ្វើខ្មែរគិតដល់ខ្លួនឯង ខ្មែរគិតកោតក្រែងសន្តានញាតិ
ខ្មែរថែសាសនាប្រទេសជាតិ ខ្មែរត្រូវមិនឃ្លាតពីសីលធម៌។
ដូច្នេះខ្មែរត្រូវតែលះបង់ ចំពោះចំណង់អន្លង់មោហ៍

ច្រណែនឈ្នានីសនាំវឹកវរ ចង់ឱ្យខ្លួនល្អកុំដៀលគេ។
អក្សរសាស្រ្តវប្បធម៌ប្រពៃណី នាទីកូនខ្មែរថែឱ្យថេរ
ជាតិគេស្រឡាញ់របស់គេ ខ្មែរត្រូវរិះរេស្រឡាញ់ខ្មែរ ។

# បុណ្យជាអ្វី

បុណ្យជាគូគាប់សំណព្វបេះដូង
បុណ្យជាគូគ្រងឆ្លងវដ្តសង្សារ
បុណ្យជាមិត្តស្មោះរួមរស់មរណា
បុណ្យជាទេវតារក្សាដួងចិត្ត ។
បុណ្យជាញាតិប្បដិសណ្ឋារៈ
បុណ្យជាអង្គរក្សអ្នកថៃជីវិត
បុណ្យជាមគ្គុទ្ទេសក៏វិសេសមែនពិត
បុណ្យជាក្រមក្រឹត្យលិខិតឱ្យសុខ។
បុណ្យជាមេស្រូបក្រសោបគុណធម៌
បុណ្យជាមេល្អបវរគ្រប់មុខ
បុណ្យជាសួស្តីជោគជ័យឈ្នះទុក្ខ
បុណ្យជាប្រមុខឱ្យសុខអម្រឹត។
បុណ្យជាអាចារ្យមានការទូន្មាន
បុណ្យជាព្រហ្មយានឆ្លងស្ពានងងឹត
បុណ្យជាកែវទិព្វលើសទេពនិម្មិត
បុណ្យបារមីពិតជីវិតដល់ត្រើយ។

# សមរភូមិក្លាខ្លាំងដេញខ្មាំងក្នុងខ្លួន

សទ្ធាជាដៃកាន់ដាវដេញខ្មាំង ជយភូមិសីលំទីតាំងកងទ័ព
វិរិយៈជាជើងប្រឹងឡើងសន្ទាប់ សមាធិជាទ្រព្យជាទ័ពកម្លាំង។
បញ្ញាជាដាវកាន់ដោយសទ្ធា គុណធម៌រួមគ្នាប្រហារពួកខ្មាំង
ឈ្នះខ្លួនឯងម្នាក់អស់អ្នកតតាំង សមរភូមិក្លាខ្លាំងដេញខ្មាំងក្នុងខ្លួន ។

# ជនទង់ខ្ពស់ល្អ

ជងទង់ត្រង់ខ្ពស់ចាំងឆ្លុះរស្មី លម្អចេតិយនៃព្រះសាស្តា
ប្រៀបដូចមកុដពេជ្រលម្អក្សត្រា ដូចហ្វូងតារាលម្អដួងខែ ។
ទង់ជាប្រធានអ្នកមានកេរ្តិ៍ឈ្មោះ បុណ្យល្អខ្ពង់ខ្ពស់មានទង់នៅក្បែរ
មើលពីចម្ងាយក៏ឃើញទង់ដែរ ទង់តាមដង្ហែបុណ្យដែលប្រណីត ។
អ្នកមានសទ្ធាមិនទាន់ខ្លាំងក្លា ឃើញទង់កាលណាជ្រះថ្លាក្នុងចិត្ត
ទង់ឈរតំណាងអ្នកសាងសុចរិត បុណ្យខ្ពង់ខ្ពស់ពិតឥតអាប់រស្មី ។
អ្នកប្រព្រឹត្តធម៌ធម៌តែងទ្រទ្រង់ អ្នកកសាងទង់ខ្ពង់ខ្ពស់ប្រពៃ

អ្នកអនុមោទនាជាអ្នកឆ្លាតវៃ ខ្ពង់ខ្ពស់ផុតភ័យជាមួយអ្នកសាង ។
បើនៅមានជាតិក៏មិនអាប់យស ចាប់ភពខ្ពង់ខ្ពស់រស់មានសំណាង
សីលទានក៏ធ្វើផងទង់ក៏សាង រក្សាព័ស្តុតាងខាងសេចក្តីសុខ ។

# គុណរបស់ទាន

ទានចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ
រហូតដល់ថ្ងៃបុត្រថ្លៃចាកគភ៌
ទានចិញ្ចឹមស្មោះទឹកដោះបបរ
កូនរស់បានល្អព្រោះធម៌សប្បុរស
ទានថ្វាយដល់សង្ឃផ្ចង់ឧទ្ទិសទាន
ប្រេតរួចពីឃ្លានព្រោះទានរំដោះ
ទានជាទេវធម៌លម្អសប្បុរស
ទានមានចិត្តស្មោះសង្គ្រោះជីវិត
ទានគឺជាទ្រព្យជាប់តាមសន្តាន
ជាមិត្តរួមប្រាណឆ្លងភពងងឹត
ទានកាច់បំបាក់មោហៈក្នុងចិត្ត
បានត្រាស់ដឹងពិតឰិតទានបារមី
ហៃកូនប្រុសស្រីគប្បីចាំទុក
គុណម្តាយឪពុកទានាធិបតី
កូនដឹងមង្គលសាមសិបប្រាំបី
ជៀសកម្មអប្រិយផុតភ័យអបាយ ។

# សេចក្តីត្រិះរិះរបស់គាងវិសាខា

សេចក្តីត្រិះរិះរបស់ខ្ញុំថា
នៅប្រាសាទថ្មីតាមទ្រព្យដែលមាន
សេចក្តីត្រិះរិះរបស់ខ្ញុំថា
ថ្វាយគ្រែពូកខ្នើយដោយចិត្តផ្ចិតផ្ចង់
សេចក្តីត្រិះរិះរបស់ខ្ញុំថា
ផ្សំដោយមំសំធ្វើដោយហ្មត់ចត់
សេចក្តីត្រិះរិះរបស់ខ្ញុំថា
ព្រមទាំងព្រះសង្ឃសទ្ធាខ្ញុំមាន

តើនៅពេលណាខ្ញុំបានថ្វាយទាន
ជាវិហារទានថ្វាយចំពោះសង្ឃ ។
តើនៅពេលណាខ្ញុំបានឱនអង្គ
ថ្វាយចំពោះសង្ឃដែលគង់ក្នុងវត្ត ។
តើនៅពេលណាខ្ញុំបានថ្វាយភត្ត
សលាកភត្តជាអាហារទាន! ។
តើនៅពេលណាជួបព្រះទ្រង់ញាណ
ថ្វាយចីវរទានសំពត់សាច់ល្អ ។

សេចក្តីត្រិះរិះរបស់ខ្ញុំថា តើនៅពេលណាជួបសង្ឃបវរ
ថ្វាយភេសជ្ជៈទឹកឃ្មុំប្រេងស្ករ ទឹកដោះគោល្អនិងទឹកអំពៅ ។
មកដល់ឥឡូវខ្ញុំបានសម្រេច គ្រប់មុខបានស្រេចឥតមានសល់នៅ
ខ្ញុំបានថ្វាយទានកប់ទុកយ៉ាងជ្រៅ ក្នុងដំណើរទៅកាន់ព្រះនិព្វាន ។

# អធិដ្ឋានការក្រាបថ្វាយបង្គំព្រះពុទ្ធចេតិយ

ខ្ញុំព្រះករុណាសូមដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះអរិយសង្ឃជាទីពឹងទីរលឹក ខ្ញុំព្រះករុណាសូមក្រាបនមស្ការបូជាព្រះគុណនៃអង្គព្រះសម្មាសម្ពុទ្ធដែលទ្រង់ពេញ-ពោរទៅដោយព្រះមេត្តា ករុណារកប្រមាណមិនបាន ព្រះអង្គទ្រង់លះបង់គ្រប់យ៉ាងក្នុងការសន្សំព្រះបារមី ដើម្បីបានត្រាស់ដឹងហើយប្រកាសធម៌នាំវេនេយ្យសត្វចេញចាកពីវដ្តៈ ។ ខ្ញុំព្រះករុណាបូជាព្រះពុទ្ធចេតិយដោយសេចក្ដីជ្រះថ្លាដ៏ក្រៃលែង ។ សូមតាំងសច្ចាធិដ្ឋាន ដោយផលានិសង្សនៃបុណ្យដែលខ្ញុំព្រះករុណា បានធ្វើក្នុងថ្ងៃនេះ សូមជាបច្ច័យឱ្យបានសម្រេចដូចសេចក្ដីប្រាថ្នា ។ អង្គព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ដឹង

ធម៌យ៉ាងណា សូមឱ្យខ្ញុំព្រះករុណាមានចំណែកនៃធម៌ របស់ព្រះអង្គក្នុងកាលដ៏សមគួរផងចុះ  ទោះបីកើតក្នុងជាតិណាៗ  សូមកើតនៅក្រោមម្លប់បវរនៃព្រះពុទ្ធសាសនា កណ្តាលកល្យាណមិត្ត បានសេពគប់នឹងសប្បុរស ដែលជាអ្នកដឹងនូវធម៌ដ៏ប្រសើរ សូមជាបុគ្គលសម្មាទិដ្ឋិ មានឱកាស សិក្សាធម៌ ស្តាប់ធម៌ ប្រព្រឹត្តធម៌ ដែលជាបច្ច័យឱ្យចម្រើនទៅដោយសតិ និងបញ្ញាបញ្ជូនតទៅគ្រប់ជាតិរហូតដល់ព្រះនិព្វានហោង។

# សម្រស់វេឡុវ័នមហាវិហារ

គ្រាមួយព្រះបាទពិម្ពិសារ
ហឫទ័យមេត្តាឱ្យគេច្រៀង
សរសើរវេឡុវ័នដោយសំនៀង
អត្ថន័យសូរសៀងពីរោះក្រៃ ។
អ្នកណាមិនឃើញវេឡុវ័ន
ដែលព្រះអរហន្តគង់អាស្រ័យ
អ្នកនោះមិនបានឃើញបុរី
ឧទ្យានប្រពៃនៃទេវតា ។
អ្នកណាបានឃើញវេឡុវ័ន
ពិតឥតធុញទ្រាន់ឥតសោកា
អ្នកនោះគឺដូចបានទស្សនា
ននន្ទវ័នអស្ចារ្យក្នុងទេវលោក ។
វត្តវេឡុវ័នកើតឡើងបាន
ដោយបុណ្យកល្យាណព្រះមានជោគ
គុណវេឡុវ័នមានក្នុងលោក
អ្នកណានឹងមករាប់អស់បាន ។

ព្រះនាងខេមាមហេសីស្ដេច ស្ដាប់ចប់ស្រេចបាច់រឿងឧទ្យាន
ហឫទ័យប៉ងទតមិនអាចខាន ខេមាកល្យាណគាល់រាជា ។
រីព្រះរាជាម្ចាស់ផែនដី ត្រាស់ថាមហេសីនាំបរិពារ
ទៅទតឧទ្យានព្រះភគវា គ្រប់គ្នានឹងបានសុខសួស្ដី ។
គ្រានោះឧទ្យានវេឡុវ័ន មានព្រះអរហន្តជាសិរី
ព្រះមានពន្លឺឆរង្សី ភ្លឺព្រោះសិរីព្រះសាស្ដា ។
វត្តវេឡុវ័នតារៅឃំ ពួស្វររងំឃ្មុំក្រេបផ្កា
ជាភ័ព្វសំណាងព្រះខេមា ជួបព្រះសាស្ដាសម្រេចធម៌ ។

# ធម៌នមស្ការព្រះពោធិសត្វទាំង ១១ ព្រះអង្គ

**១. តេមិយោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វ ព្រះនាម តេមិយ ញុំាងព្រះទ័យ ឱ្យប្រព្រឹត្តទៅជាអារម្មណ៍ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ នេក្ខម្ម បារមី, នេក្ខម្ម ឧបបារមី, នេក្ខម្ម បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**២. មហាជនកោ ពោធិសត្តោ នាម ភគវា ចិត្ត វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វ ព្រះនាម មហាជនក ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជា អារម្មណ៍ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ វីរិយ បារមី, វីរិយ ឧបបារមី, វីរិយ បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៣. សុវណ្ណសាមោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម សុវណ្ណសាម ញុំាងព្រះ ទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះបានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ មេត្តា បារមី, មេត្តា ឧបបារមី, មេត្តា បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៩.នេមិរាជា ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម នេមិរាជ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជា

ព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ អធិដ្ឋាន បារមី, អធិដ្ឋាន ឧបបារមី, អធិដ្ឋាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៥. មហោសថោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសល ធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វ ព្រះនាម មហោសថ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ បញ្ញា បារមី, បញ្ញា ឧបបារមី, បញ្ញា បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៦. ភូរិទត្តោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសល ធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម ភូរិទត្ត ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ សីល បារមី, សីល ឧបបារមី, សីល បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៧. ចន្ទកុមារោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម ចន្ទកុមារ ញ៉ាំងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ ខន្តិ បារមី, ខន្តិ ឧបបារមី, ខន្តិ បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៨. ព្រហ្មនារទោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម ព្រហ្មនារទ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ ឧបេក្ខា បារមី, ឧបេក្ខា ឧបបារមី, ឧបេក្ខា បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**៩. វិធូរោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម វិធូរៈ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជា

ព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ សច្ចំ បារមី, សច្ចំ ឧបបារមី, សច្ចំ បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**១០. វេស្សន្តរោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម វេស្សន្តរ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះ ទ្រង់ព្រះនាមថា សម្មាសម្ពុទ្ធោ ដោយកុសលធម៌ទាំងឡាយនោះ ។

**ឥតិបិ ទាន បារមី, ទាន ឧបបារមី, ទាន បរមត្ថបារមី សម្បន្នោ សោ ភគវា ។**

**១១. សិទ្ធត្ថោ ពោធិសត្តោ នាម ភគវា ចិត្តំ វត្តកំ អារម្មណំ ត្វំបិ ពុទ្ធោ មេ ភវិស្សតិ កុសលធម្មា សម្មាសម្ពុទ្ធោ ឥតិបិ សោ ភគវា ។**

ព្រះដ៏មានព្រះភាគអង្គនោះ កាលនៅជាពោធិសត្វព្រះនាម សិទ្ធត្ថ ញុំាងព្រះទ័យឱ្យប្រព្រឹត្តទៅជាអារម្មណ៍ ដោយទូន្មានខ្លួនថា អ្នកឯងនឹងបានត្រាស់ជាព្រះពុទ្ធក្នុងកាលជាអនាគត ព្រោះហេតុនោះ បានជាព្រះដ៏មានព្រះភាគអង្គនោះទ្រង់ព្រះនាមថាសម្មាសម្ពុទ្ធោដោយកុសលធម៌ទាំងឡាយនោះ ។[១]

[១] (ចាកធម៌នមស្ការព្រះរតនត្រ័យ) ដោយ ស.ដ.វ.ថ

# គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ ៤ គាថា

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**សព្វញ្ញូសិ មហាវីរ លោកជេដ្ឋ នរាសភ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញុពុទ្ធ ។[១]

**នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម**
**ពហុជ្ជនំ តារយសិ ទេសេន្តោ អមតំ បទំ ។**

---

[១] បិ.៧៤/១៩

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ បពិត្រព្រះអង្គជាបុរសឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វាន ញុំាងជនដ៏ច្រើនឱ្យឆ្លងវដ្តទុក្ខបាន ។[១]

**រូបេ សីលេ សមាធិម្ហិ បញ្ញាយ ច អសាទិសោ**
**វិមុត្តិយា អសមសមោ ធម្មចក្កប្បវត្តនេ ។**

ព្រះអង្គមិនមានបុគ្គលស្មើក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើចំពោះវិមុត្តិធម៌ និងការញុំាងធម្មចក្កឱ្យប្រព្រឹត្តទៅ ។[២]

[១] បិ.៧៣/១៨៨, [២] បិ.៧៧/១៣

**លាភាលាភេ ន សជ្ជន្តិ សម្មានេ វិមានេ**
**បឋវីសទិសា ពុទ្ធា តស្មា តេ ន វិរោធិយា ។**

ព្រះពុទ្ធទាំងឡាយ មានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភនិងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឱ្យឆ្គាំឆ្គង នឹងព្រះពុទ្ធទាំងនោះឡើយ ។[១]

[១] បិ.៧២/១០៨

# គាថាសរសើរគុណព្រះសម្មាសម្ពុទ្ធ

(១) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, ព្រះអង្គ ទ្រង់ឃើញនូវមហាជន ដោយព្រះសព្វញ្ញុតញ្ញាណមិនមានទោស សូម្បី ពួកអមនុស្ស ក៏នាំគ្នានមស្ការព្រះអង្គដែរ ។

(២) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**សទេវកស្មិំ លោកស្មិំ, នត្ថិ តេ បដិបុគ្គលោ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោក ព្រមទាំងទេវលោក។

(៣) **តុវំ ពុទ្ធោ តុវំ សត្ថា, តុវំ មារាភិភូ មុនិ;**
**តុវំ អនុសយេ ឆេត្វា, តិណ្ណោ តារេសិ មំ បជំ ។**

ព្រះអង្គជាសព្វញ្ញុពុទ្ធ ព្រះអង្គជាគ្រូតាមបង្រៀន ព្រះអង្គជាអ្នកប្រាជ្ញ គ្របសង្កត់នូវមារទាំងអស់ ព្រះអង្គទ្រង់កាត់បង់នូវអនុស័យ ឆ្លង (អន្លង់ដ៏ធំគឺសំសារ ដោយព្រះអង្គឯង) ហើយ ញុំាំងពពួកសត្វនេះឱ្យឆ្លងផងដែរ។

(៨) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**អត្តានំ តោសយិត្វាន, បរេ តោសេសិ ត្វំ មុនិ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាអ្នកប្រាជ្ញ ព្រះអង្គទ្រង់ញុំាងខ្លួនព្រះអង្គឱ្យត្រេកអរហើយ ទ្រង់ញុំាងពួកជនដទៃឱ្យត្រេកអរផងដែរ។

(៩) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**ញាណេន តេ សមោ នត្ថិ, យាវតា ញាណមុត្តមំ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ,

បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, សភាវៈជាគ្រឿងដឹងស្មើដោយព្រះញាណព្រះអង្គ មិនមានឡើយ, ញាណរបស់ព្រះអង្គដ៏ឧត្តមយ៉ាងក្រៃលែង។

(៦) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**ពហុជ្ជនំ តារយសិ, ទេសេន្តោ អមតំ បទំ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, ព្រះអង្គសម្តែងនូវអមតបទ គឺព្រះនិព្វាន តែងចម្លងជនច្រើន(ឱ្យដល់នូវត្រើយគឺព្រះនិព្វាន)។

(៧) **នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;**
**សព្វញ្ញូសិ មហាវីរ, លោកជេដ្ឋ នរាសភ ។**

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសខ្ពង់ខ្ពស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាចម្បងក្នុងលោក ប្រសើរជាងនរជន ព្រះអង្គជាព្រះ-សព្វញ្ញូ ជ្រាបនូវរឿងសព្វគ្រប់ ។

(៨) **នមោ តេ ពុទ្ធ វីរត្ថុ, វិប្បមុត្តោសិ សព្វធិ;**
**ព្យសនម្ហិ អនុប្បត្តោ, តស្ស មេ សរណំ ភវ ។**

បពិត្រព្រះពុទ្ធ ទ្រង់ជាវីរជន ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, ព្រះអង្គរួចផុតស្រឡះចាកកិលេសទាំងពួង, ខ្ញុំព្រះអង្គដល់នូវសេចក្តីវិនាស សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ។

(៩) **នមោ តេ ពុទ្ធ វីរត្ថុ, វិប្បមុត្តោសិ សព្វធិ;**
**សម្ពាធបដិបន្នោស្មិ, តស្ស មេ សរណំ ភវ ។**

បពិត្រព្រះពុទ្ធ ទ្រង់ជាវីរជន ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, ព្រះអង្គរួចផុតស្រឡះចាកធម៌ទាំងពួង មានខន្ធនិងអាយតនៈជាដើម; ខ្ញុំព្រះអង្គកំពុងដល់នូវគ្រោះដ៏ចង្អៀត, សូមព្រះអង្គជាទីពឹងរបស់ខ្ញុំ។

**នមោ តេ វាទិសូទន, នមោ តេ ឥសិសត្តម;**
**នមោ តេ សព្វលោកគ្គ, នមោ តេ អភយង្ករ ។**

បពិត្រព្រះអង្គទ្រង់បង្ហូរ នូវពាក្យប្រៀនប្រដៅ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ,បពិត្រព្រះអង្គទ្រង់ជាឥសិទី៧ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រ

ព្រះអង្គជាបុគ្គលប្រសើរជាងសត្វលោកទាំងអស់ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ធ្វើនូវអភ័យ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ។

(១០) **នមោ តេ មារមថន, នមោ តេ ទិដ្ឋិសូទន;**

**នមោ តេ សន្តិសុខទ, នមោ តេ សរណង្ករ ។**

បពិត្រព្រះអង្គទ្រង់ញាំញីនូវមារ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់បង្ហូរនូវពាក្យប្រៀនប្រដៅ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ប្រទាន នូវសន្តិសុខ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ធ្វើនូវទីពឹង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ។

(១១) **នមោ តេ សព្វទស្សាវិ, នមោ តេ ករុណាករ;**

**នមោ តេ តិណ្ណសំសារ, នមោ តេ អមតំ ទទ ។**

បពិត្រព្រះអង្គទ្រង់ឃើញនូវហេតុផលទាំងពួង ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គទ្រង់ធ្វើនូវករុណា ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់មានសំសារឆ្លងផុតហើយ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គទ្រង់ប្រទាននូវអមតធម៌ ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ។

(១២) **នមោ តេ លោកឧប្បន្ន, នមោ តេ ឯកបុគ្គល;**

**នមោ តេ វរសព្វញ្ញូ, នមោ តេ លោកកម្បក ។**

បពិត្រព្រះអង្គទ្រង់កើតឡើងក្នុងលោកហើយ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុគ្គលឯក ខ្ញុំសូមនមស្ការចំពោះព្រះអង្គ,

បពិត្រព្រះអង្គជាសព្វញ្ញូដ៏ប្រសើរ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ,បពិត្រព្រះអង្គទ្រង់អនុគ្រោះដល់សត្វលោក ខ្ញុំសូមនមស្ការ ចំពោះព្រះអង្គ។

(១៣) **អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;**
**យស្មិំ ឧប្បជ្ជមានម្ហិ, បថវី សម្បកម្បតិ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ! កិរិយាដែលយើងបានជួបបានទាន់ព្រះសាស្តា គួរជ្រះថ្លាមែនហើយ! ព្រោះកាលដែលព្រះអង្គត្រាស់ដឹង(ក្នុងលោក) សូម្បីផែនដីក៏កក្រើកញាប់ញ័រដែរ។

(១៤) **អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;**

**ឯកច្ឆត្តស្ស ទានេន, ទុគ្គតិំ នុបបជ្ជហំ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! កិរិយាដែលយើងបានជួបបានទាន់ព្រះសាស្តា គួរជ្រះថ្លាមែនហើយ! (ព្រោះថា) ខ្ញុំមិនដែលចូលទៅកើតក្នុងទុគ្គតិ ដោយហេតុតែការឱ្យឆត្រមួយ។

(១៩) **អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;**

**អចេតនាបិ តុរិយា, សយមេវ បវជ្ជរេ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ! ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែន ហើយ! កិរិយាដែលយើងបានជួបបានទាន់ព្រះសាស្តា គួរជ្រះថ្លា

មែនហើយ! (ព្រោះថា) គួរឲ្យតន្ត្រីស្ញប់ស្ញែងតចេតនាសោះ ក៏ប្រគំដោយខ្លួនឯងបានដែរ។

(១៦) **អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;**
**កឡេវរំ មេ បតិតំ, ទេវលោកេ រមាមហំ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ កិរិយាដែលយើងបានជួបបានទាន់ព្រះសាស្តា គួរជ្រះថ្លាមែនហើយ (ព្រោះថា) រាងកាយរបស់ខ្ញុំដួលចុះស្លាប់ហើយ, ខ្ញុំបានត្រេកអរក្នុងទេវលោក។

(១៧) **អហោ ពុទ្ធោ អហោ ធម្មោ, អហោ នោ សត្ថុ សម្បទា;**

**ពុទ្ធស្ស អានុភាវេន, វសុធាយំ បកម្បថ ។**

ព្រះពុទ្ធដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ ព្រះធម៌ដ៏អស្ចារ្យ គួរជ្រះថ្លាមែនហើយ កិរិយាដែលយើងបានជួបបានទាន់ព្រះសាស្តា គួរជ្រះថ្លាមែនហើយ (ព្រោះថា) ផែនដីនេះ បានកម្រើកញាប់ញ័រហើយ ដោយអានុភាពនៃព្រះពុទ្ធ។

(១៨) **តញ្ច អច្ឆរិយំ ទិស្វា, អព្ភុតំ លោមហំសនំ;**
**ពុទ្ធេ ចិត្តំ បសាទេមិ, ទ្វិបទិន្ទម្ហិ តាទិនេ ។**

ខ្ញុំឃើញនូវហេតុ ដ៏អស្ចារ្យ ចំឡែក គួរព្រឺរោមនោះ ក៏ញុំាងចិត្តឱ្យជ្រះថ្លាក្នុងព្រះពុទ្ធ ជាធំជាងសត្វជើងពីរ ទ្រង់មិនញាប់ញ័រដោយលោកធម៌ទាំង ៨ ឡើយ។

## អាគតដ្ឋាននៃគាថា

គាថា ១ (បិ.១៩/១០០)

គាថា ២ (ថេរគាថា បិ.៥៧/៦៨)

គាថា ៣ (ម.ម.សេលត្ថេរ ២៥/៥៤,
ខុ.សុ.សភិយត្ថេរ ៥៤/១៨២, ខុ.ថេរ. ៥៧/៦៨)

គាថា ៤ (សុមង្គលត្ថេរ បិ.៧៣/១៧)

គាថា ៥ (ញាណសញ្ញិកត្ថេរ បិ.៧៣/៤៦)

គាថា ៦ (ថោមកត្ថេរបិ.៧៣/១៨៨)

គាថា ៧ (អាសនត្ថេរ បិ.៧៤/១៩)

គាថា ៨ (សម្បសាទិកត្ថេរ បិ.៧៤/៦)

គាថា ៩ (ចន្ទិមសូរិយ បិ.២៩/២៣២, ២៣៣)

គាថា ១០ (បិ.៧៥/៣៧៥)

គាថា ១១ (ខេមាថេរី បិដកលេខ ៧៦/៩០)

គាថា ១២ (មមគាថា)

គាថា ១៣ (ពុទ្ធសញ្ញិកត្ថេរ បិដកលេខ៧៣/២៥)

គាថា ១៤ (សបរិវារឆត្តទាយកត្ថេរ បិ.៧៤)

គាថា ១៥ (បាដិហីរសញ្ញកត្ថេរ បិដកលេខ៧៥)

គាថា ១៦ (គន្ធោទកិយត្ថេរ បិដកលេខ៧២)

គាថា ១៧ (៧៣/១៥)

គាថា ១៨ (មហាបរិវារកត្ថេរ បិដកលេខ៧៣/១៥)

# បទដ៏ប្រសើរ[១]

**ពុទ្ធោតិ វចនំ សេដ្ឋំ, ពុទ្ធោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ ។**

ពាក្យថា **ពុទ្ធោ** ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា **ពុទ្ធោ** ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្ដាប់ក្នុងលោក ស្មើដោយពាក្យថា **ពុទ្ធោ** ពុំមានឡើយ ។

**ធម្មោតិ វចនំ សេដ្ឋំ, ធម្មោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ ។**

ពាក្យថា **ធម្មោ** ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា **ធម្មោ** ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្ដាប់ក្នុងលោក ស្មើដោយពាក្យថា **ធម្មោ** ពុំមានឡើយ ។

---

[១] ចាកមធុរសវាហិនី អហិតុណ្ឌិកវត្ថុកថា ទំ.៨៩

**សង្ឃោតិ វចនំ សេដ្ឋំ, សង្ឃោតិ បទមុត្តមំ**
**នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ ។**

ពាក្យថា **សង្ឃោ** ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា **សង្ឃោ** ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃ ដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្តាប់ក្នុងលោក ស្មើដោយពាក្យថា **សង្ឃោ** ពុំមានទៀយ ។

**តស្ស មុខំមុខំ នាម, យំ វត្តតិ មុខេ សទា,**
**ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ ។**

ពាក្យថា **ព្រះពុទ្ធ** ជាពាក្យដែលសត្វលោករកបានដោយកម្រ អាចឱ្យនូវសម្បត្តិទាំងពួង ប្រព្រឹត្តទៅក្នុងមាត់របស់បុគ្គលណាសព្វៗ កាល, មាត់របស់បុគ្គលនោះ បានឈ្មោះថា មាត់ល្អប្រពៃ មាត់មានលាភដោយពិត ។

**តស្ស មនោ មនោ នាម, យំ ចេ មនសិ វត្តតិ,**
**ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ ។**

ពាក្យថា **ព្រះពុទ្ធ** ជាពាក្យដែលសត្វលោករកបានដោយកម្រ អាចឱ្យនូវសម្បត្តិទាំងពួង ប្រព្រឹត្តទៅក្នុងចិត្តរបស់បុគ្គលណាហើយ ចិត្តរបស់បុគ្គលនោះ បានឈ្មោះថា ចិត្តប្រពៃ ចិត្តមានលាភដោយពិត ។

**តស្សេវ សោតំ សោតំវ, យំ សុណាតិ ជនោ អយំ**
**ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ ។**

បុគ្គលណាបានស្តាប់នូវពាក្យថា **ព្រះពុទ្ធ** ជាពាក្យដែលសត្វលោករកបានដោយកម្រ អាចឱ្យនូវសម្បត្តិទាំងពួង ដូច្នេះថា “បុគ្គលនេះជាអង្គព្រះជិនស្រី” សោតប្បសាទរបស់បុគ្គលនោះ បានឈ្មោះថា សោតប្បសាទល្អប្រពៃ សោតប្បសាទមានលាភដោយពិត ។

**សហស្សសីសោបិ ចេ បោសោ សីសេសីសេ សតំមុខា**
**មុខេមុខេ សតំជីវ្ហា ជីវិកប្បោ មហិទ្ធិកោ**
**ន សក្កោតិ ច វណ្ណេតុំ និស្សេសំ សត្ថុនោ គុណំ ។**

ប្រសិនបើមានបុរសណាមួយ មានក្បាលមួយពាន់ ក្នុងក្បាលមួយៗ មានមាត់មួយរយៗ ក្នុងមាត់មួយៗ មានអណ្ដាតមួយរយៗ មានអាយុមួយកប្ប មានឫទ្ធិច្រើន (ជាអ្នកសរសើរគុណព្រះពុទ្ធទាំងយប់ទាំងថ្ងៃ ដរាបដល់អស់អាយុប៉ុណ្ណោះ) ក៏ពុំអាចនឹងពណ៌នាគុណ ព្រះសាស្ដាឱ្យអស់មិនឱ្យសេសសល់បានឡើយ ។ (ត្រៃរត្នវិនិច្ឆ័យ ទំ.៦)

**មហាការុណិកំ ពុទ្ធំ ធម្មញ្ច វិមលំ វរំ**
**វន្ទេ អរិយសំឃញ្ច ទក្ខិណេយ្យំ និរង្គណំ ។**

ខ្ញុំសូមថ្វាយបង្គំព្រះពុទ្ធ ទ្រង់ប្រកបដោយមហាករុណា ព្រមទាំងព្រះធម៌ដ៏ប្រាសចាកមន្ទិលដ៏ប្រសើរ និងព្រះអរិយសង្ឃលោកជាទក្ខិនេយ្យបុគ្គលមិនមានកិលេស ។[១]

**អនន្តករុណាបញ្ញំ តថាគតមនុត្តរំ**
**វន្ទិត្វា សិរសា ពុទ្ធំ ធម្មំ សាធុគណម្បិច ។**

ខ្ញុំសូមថ្វាយបង្គំព្រះពុទ្ធ ទ្រង់ជាព្រះតថាគត ទ្រង់ប្រសើរលើស ទ្រង់មានករុណា និងបញ្ញារកទីបំផុតគ្មាន ព្រមទាំងព្រះធម៌និងព្រះអរិយសង្ឃ ដោយសិរសា ។[២]

---

[១] គន្ថារម្ភកថា នៃគម្ពីរសារត្ថទីបនីដីកា, [២] គន្ថារម្ភកថា នៃគម្ពីរអភិធម្មាវតារ

**នមស្សាមី តិលោកគ្គំ ញេយ្យសាគរបារគុំ**
**ភវាភវករំ ធម្មំ គណញ្ច គុណសាគរំ។**

ខ្ញុំសូមនមស្ការព្រះពុទ្ធ ទ្រង់ប្រសើរលើសក្នុងត្រៃលោក ទ្រង់ដល់ត្រើយនៃសាគរ គឺគឺញេយ្យធម៌ ព្រមទាំងព្រះធម៌ដែលធ្វើការមិនមាននៃភព និងព្រះសង្ឃលោកជាសាគរនៃគុណធម៌ ។[១]

**សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ**
**នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។**

ខ្ញុំព្រះអង្គនោះនឹងត្រាច់ទៅអំពីស្រុកមួយទៅស្រុកមួយ អំពីបុរីមួយ ទៅកាន់បុរីមួយ នមស្ការនៅព្រះសម្ពុទ្ធផង នូវភាពនៃធម៌ ជាធម៌ដ៏ល្អផង ។[២]

---

[១] សច្ចសង្ខេប, [២] ឧបាលិត្ថេរាបទាន បិ.៧២/១១០

# រលឹកដល់ព្រះរតនត្រៃរឿយៗ ឈ្មោះជាសាវ័កល្អ

**សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ ពុទ្ធគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះពុទ្ធគុណអស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រលឹកៗ ដោយប្រពៃសព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ ធម្មគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះធម្មគុណអស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រលឹកៗ ដោយប្រពៃសព្វកាល ។

**សុប្បពុទ្ធំ បពុជ្ឈន្តិ, សទា គោតមសាវកា;**
**យេសំ ទិវា ច រត្តោ ច, និច្ចំ សង្ឃគតា សតិ ។**

សតិរបស់ជនពួកណា ដែលឋិតនៅក្នុងព្រះសង្ឃគុណអស់កាលជានិច្ច ទាំងថ្ងៃទាំងយប់ ជនពួកនោះ ឈ្មោះថា សាវ័ករបស់ព្រះគោតម រមែងភ្ញាក់រលឹកៗ ដោយប្រពៃសព្វកាល ។[១]

**បូជារហេ បូជយតោ, ពុទ្ធេ យទិ ច សាវកេ;**
**បបញ្ចសមតិក្កន្តេ, តិណ្ណសោកបរិទ្ទវេ ។**
**តេ តាទិសេ បូជយតោ, និព្វុតេ អកុតោភយេ;**
**ន សក្កា បុញ្ញំ សង្ខាតុំ, ឥមេត្តមបិ កេនចិ ។**

កាលបុគ្គលបូជាដល់បូជារហបុគ្គល គឺព្រះពុទ្ធ ឬសាវ័ករបស់ព្រះពុទ្ធ ដែលកន្លងផុត

[១] គាថាធម្មបទ បកិណ្ណកវគ្គ

បបញ្ចធម៌ ដែលកន្លងផុតសេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ឬកាលបុគ្គលបូជាដល់បូជារហ-បុគ្គលទាំងនោះ ដែលប្រកបដោយតាទិគុណ លោកមិនមានភ័យអំពីទីណាសូម្បីនិព្វានទៅហើយ បុគ្គលណាមួយមិនអាចរាប់បុណ្យថា បុណ្យនេះមានប្រមាណប៉ុណ្ណេះបានឡើយ ។[១]

**សមាគតា ពហូ ពុទ្ធា, អរហន្តា ច សព្វសោ;**
**សម្ពុទ្ធេ អរហន្តេ ច, វន្ទមានា នមស្សថ ។**

ព្រះពុទ្ធ និងព្រះអរហន្តច្រើនព្រះអង្គ បានមកជួបជុំគ្នាដោយសព្វគ្រប់ហើយ អ្នកទាំងឡាយ ចូរថ្វាយបង្គំនមស្ការ ចំពោះព្រះសម្ពុទ្ធ និងព្រះអរហន្តចុះ ។

**ឯវំ អចិន្តិយា ពុទ្ធា, ពុទ្ធធម្មា អចិន្តិយា;**
**អចិន្តិយេ បសន្នានំ, វិបាកោ ហោតិ អចិន្តិយោ ។**

---

[១] គាថាធម្មបទ ពុទ្ធវគ្គ

ព្រះពុទ្ធទាំងឡាយ ជាអចិន្តេយ្យបុគ្គល (បុគ្គលដែលគេមិនគប្បីគិតកើត) ធម៌របស់ព្រះពុទ្ធ ជាអចិន្តិយធម៌យ៉ាងនេះ កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ រមែងបានផលជាអចិន្តិយៈ ។[១]

**យោ ចេ បូជេយ្យ សម្ពុទ្ធំ, តិដ្ឋន្តំ លោកនាយកំ;**
**ធាតុំ សាសបមត្តម្បិ, និព្វុតស្សាបិ បូជយេ ។**
**សមេ ចិត្តប្បសាទម្ហិ, សមំ បុញ្ញំ មហគ្គតំ;**
**តស្មា ថូបំ ករិត្វាន, បូជេហិ ជិនធាតុយោ ។**

បុគ្គលណាបូជាព្រះសម្ពុទ្ធជាលោកនាយក ដែលទ្រង់គង់ព្រះជន្មនៅក្តី បូជាព្រះសារីរិកធាតុ ប្រមាណប៉ុនគ្រាប់ស្ពៃ របស់ព្រះសម្ពុទ្ធដែលបរិនិព្វានហើយក្តី កាលបើមានសេចក្តីជ្រះថ្លា

---

[១] បិ.៧២/១៥

ស្មើ បុណ្យជាមហគ្គតកុសលស្មើគ្នា (គង់ចម្រើនដល់បុគ្គលនោះ) ហេតុនោះ អ្នកចូរធ្វើព្រះស្តូបបញ្ចុះព្រះសារីរិកធាតុ របស់ព្រះជិនស្រីចុះ ។[១]

**ចត្តារោ លោកេ បជ្ជោតា, បញ្ចមេត្ថ ន វិជ្ជតិ;**
**ទិវា តបតិ អាទិច្ចោ, រត្តិមាភាតិ ចន្ទិមា ។**
**អថ អគ្គិ ទិវារត្តិំ, តត្ថ តត្ថ បកាសតិ;**
**សម្ពុទ្ធោ តបតំ សេដ្ឋោ, ឯសា អាភា អនុត្តរា ។**

ពន្លឺក្នុងលោកនេះមានតែ ៤ យ៉ាង មិនមានដល់ ៥ យ៉ាងទេ គឺព្រះអាទិត្យភ្លឺក្នុងវេលាថ្ងៃ ព្រះចន្ទភ្លឺក្នុងវេលាយប់ ឯភ្លើងភ្លឺក្នុងទីនោះៗ ទាំងយប់ទាំងថ្ងៃ ព្រះសម្ពុទ្ធប្រសើរលើសពន្លឺទាំងឡាយ ពន្លឺនេះមិនមានពន្លឺដទៃលើសលប់ឡើយ ។[២]

---

[១] បិ.៧៣/២៨, [២] បិ.២៩/១២៣

# ពាក្យឧទ្ទិសបុណ្យ

**ឥទំ វោ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ**[១]

ទាននេះ ចូរមានដល់ញាតិទាំងឡាយ សូមញាតិទាំងឡាយ បានដល់នូវសេចក្តីសុខ។

# ពាក្យផ្សាយមេត្តាចិត្ត

**សុខិនោវា ខេមិនោ ហោន្តុ សព្វេសត្តា ភវន្តុ សុខិតត្តា**[២]

សព្វទាំងឡាយទាំងពួង សូមឲ្យមាននូវសេចក្តីសុខ ឲ្យមានសេចក្តីក្សេម
ឲ្យមានខ្លួនដល់នូវសេចក្តីសុខចុះ។

---

[១] តិរោកុឌ្ឍសូត្រ បិ.៥២/១៣

[២] ករណីយមេត្តសូត្រ (តាមច្បាប់ឆដ្ឋសង្គាយនា "សុខិនោវ ខេមិនោ ហោន្តុ សព្វសត្តា ភវន្តុ សុខិតត្តា")

# របៀបសំពះតាមប្រពៃណីខ្មែរ

## របៀបទី ១ គឺសំពះព្រះពុទ្ធ ទេវតា ឥន្ទព្រហ្ម ឬបួសស្នង ។

(ដាក់ចុងម្រាម ខាងលើចិញ្ចើម)



# របៀបទី ២ គឺសំពះព្រះសង្ឃ ព្រះមហាក្សត្រ និងវត្ថុស័ក្តិសិទ្ធ ។

## (ដាក់ចុងមេដៃត្រឹមចិញ្ចើម)



# របៀបទី ៣ គឺ សំពះឪពុកម្តាយ យាយតា លោកគ្រូ អ្នកគ្រូ ។

(ដាក់ចុងម្រាម ត្រឹមចុងច្រមុះ)



# របៀបទី ៤ គឺសំពះ អ្នកមានអាយុច្រើន ឋានៈធំជាង

(ដាក់ចុងម្រាម ត្រឹមបបូរមាត់)



# របៀបទី ៩ គឺសំពះ អ្នកមានអាយុស្មើគ្នា ឬប្រហាក់ប្រហែលគ្នា (ដាក់ដៃត្រឹម ដើមទ្រូង)



# អានិសង្សការសំពះ

ធម៌ គឺពរទាំងឡាយ ៤ ប្រការ គឺ អាយុ ពណ៌សម្បុរកាយ សេចក្តីសុខ និងកម្លាំង រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រៃ ជាប្រក្រតី និងអ្នកដែលមានសេចក្តីចម្រើនគុណមានសីល-គុណជាដើម ឬអ្នកដែលចម្រើនដោយវ័យ គឺចាស់ព្រឹទ្ធាចារ្យ ។០៚

# របៀបថ្វាយបង្គំ

ត្រូវអង្គុយលុតជង្គង់តាមបែបទេវបុត្រ (សម្រាប់បុរស) ឬអង្គុយលុតជង្គង់បែបទេពធីតា (សម្រាប់ស្ត្រី) រួចលើកដៃឡើងប្រណម្យដាក់ឲ្យចំទ្រូង បន្ទាប់មកលើកដៃឡើងប្រណម្យដាក់ដល់ថ្ងាស មេដៃទាំងពីរដាក់ត្រឹមចិញ្ចើម ក្រាបចុះឲ្យថ្ងាសដល់ទល់នឹងផ្ទៃកន្ទេល ឬដាក់បាតដៃផ្កាប់ឲ្យរាបឃ្លាតពីគ្នាប្រហែលមួយទះ[១] ។

[១] ខ្នាតរង្វាស់ប្រវែងខ្មែរពីបុរាណ ដោយគិតប្រវែងទទឹងបាតដៃផ្កាប់ ។

## រូបឧទាហរណ៍សម្រាប់បុរស



# រូបឧទាហរណ៍សម្រាប់ស្ត្រី



# នាមសប្បុរសជនចូលរួមបោះពុម្ពសៀវភៅ

-លោកម្ចាស់គ្រូសីលសំវរត្ថេរោ **នៅ ច័ន្ទវាសនា** (ព្រះចៅអធិការវត្តភ្នំអណ្តើក)

-ភិក្ខុសច្ចកល្យាណោ **នួន សាឡឿន** (គ្រូសូត្រឆ្វេង)..........................................៥០ដុល្លា

-ព្រះមហារតនសុភោ **សូ សារុន** ............................................................១០០,០០០រៀល

-សាមណេរគុណវឌ្ឍនោ **ម៉ាត ពិសិទ្ធិ** ................................................ ៨០,០០០រៀល

-ឧបាសក **ឡាត់ សួយ** និងឧបាសិកា **ខៅ ឆារី** ព្រមទាំងកូនចៅ..........១០០,០០០រៀល

-ឧបាសិកា **សុខ ស្រីស្រស់**..................................................................... ៥ដុល្លា

ដោយអំណាចកុសលធម្មទាននេះ
សូមឲ្យបានជាបច្ច័យនៃការអស់អាសវក្កិលេសក្នុងកាលដ៏ខ្លី
កុំបីអាក់ខានឡើយ ។

ពុទ្ធោតិ វចនំ សេដ្ឋំ ពុទ្ធោតិ បទមុត្តមំ

នត្ថិ តេន សមំ លោកេ អញ្ញំ សោតរសាយនំ ។

វត្តកច្ឆបបព៌ត “ភ្នំអណ្ដើក” ភូមិក្រពើជើង ឃុំភ្នំសំពៅ ស្រុកបាណន់ ខេត្តបាត់ដំបង